# ១១.រឿងកំណើតសត្វឆ្មា

អតីតេ ក្នុងកាលនោះមានមហាឥសីមួយអង្គ គង់នៅព្រៃភ្នំមួយឈ្មោះ វុឌ្ឍីបពិត តាំងចង្ក្រមភាវនាក្នុងទីភ្នំនោះ ជាអង្វែងឆ្នាំមក ។ នៅកន្លែងនោះ មានស្រះបួនគឺទិស បូព៌ា ១ ទក្សិណ ១ បស្ចិម ១ និងឧត្តរ ១ ។ ស្រះនោះមានទឹករងថ្លា មានដុះឈូកក្រហមឈូកស និងបុប្ផាផងទាំងពួង ជាទីសប្បាយនៃមច្ឆាគ្រប់បែប ឯមាត់ច្រាំងក៏ជ្រាល មុខគួរឲ្យសប្បាយពេកណាស់ ។ ស្រះទាំងបួននៅឆ្ងាយពីអាស្រមប្រហែលមួយយោជន៍ ព្រះឥសីក៏ធ្លាប់តែទៅស្រង់ទឹករាល់ដងផង ។ មានសម័យថ្ងៃមួយ ព្រះឥសីគង់ចម្រើនមេត្តាភាវនាដោយញាណឈានលោកិយ សព្វគ្រប់ទៅឃើញថា: ឱ ! មានទេពធីតាមកចាប់កំណើត ក្នុងផ្កាឧត្បល ដែលដុះក្នុងស្រះខាងឧត្តរ បានអាយុ ៩ ថ្ងៃហើយ តើអាត្មាអញក៏ខានទៅស្រង់ទឹកឯស្រះនោះ ៩ ថ្ងៃហើយដែរ ។ ព្រះឥសីក៏ដាក់ស្មឹងស្មាធិ៍គិតថា អាត្មាអញគួរទៅយកមកចិញ្ចឹមបីបាច់ថែរក្សាចុះ គិតហើយក៏រៀបអង្គផ្ទង់ដំណើរ តម្រង់ទៅទិសឧត្តរ ដល់ស្រះហើយ ព្រះឥសីឈរសម្លឹងមើលគ្រប់ផ្កាឃើញផ្កាឧត្បលមួយធំខ្ពស់ ឃើញនាងទេពធីតាអង្គុយក្នុងផ្កានោះ ព្រះឥសីក៏ចុះទៅកាច់យកផ្កានោះមក ហើយនិមន្តត្រឡប់មកកាន់អាស្រមវិញ ចិញ្ចឹមថែរក្សាជាសុខសប្បាយ ។ លុះដល់នាងធំ ក៏ឲ្យឈ្មោះថា " ឧត្តរបុប្ផា " លុះបានអាយុ ១៥ វស្សា លោកតាក៏ភ្នកព្រះទ័យនឹក អាណិតចៅស្រី ព្រោះពេញរូបរាងទៅហើយ នៅកំព្រាឥតគ្នីគ្នានឹងលេងប្រឡែង ឯកឯងអផ្សុកវិតក្កចិត្ត ដូច្នេះគួរអញយកបុប្ផាមួយទៀតមកជបឲ្យកើតជាគ្នា គ្រាន់បានជាពីរនាក់ ។ ព្រះឥសីគិតហើយ ឈ្វេងយល់ថា ឥឡូវបើយកផ្កាដទៃផ្សេងមកជបជាមនុស្សទៅ ឃើញថាជាជាតិផ្កាដូចគ្នា ដូច្នេះចាំយកជាតិពីនាងផ្ទាល់វិញ ។ ឥសីគិតហើយក៏ហៅនាង ឧត្តរបុប្ផាមកផ្តាំថា បើកាលណានាងធំពេញរាងហើយ មានរដូវ ចូរនាងផ្ចិតសំឡីឲ្យទុកឲ្យតា ៗ នឹងជបឲ្យបានគ្នាគ្រាន់នឹងលេងពីរនាក់ ។ នាងឧត្តរបុប្ផាបានឮលោកតាមានពុទ្ធដីកាហើយ ក៏ត្រេកអរពន់ពេក លុះដល់គម្រប់ពេលមានរដូវកាលណាហើយ នាងក៏យកទៅថ្វាយលោកតាតាមបណ្តាំ ។

លោកតាប្រាប់ទៅនាងថា៖ អើចៅ ! ថ្ងៃស្អែកនេះចៅនឹងបានគ្នាជាពីរនាក់ គ្រាន់និយាយលេងសោះអផ្សុកហើយ ។ វេលាយប់នោះ នាងដេកពុំលក់សោះ ទន្ទឹងចាំតែព្រឹកឆាប់ នឹងអាលបានគ្នាជាពីរនាក់ ។ លុះព្រឹកឡើង លោកតាក៏បិទទ្វារកុដិ តាំងវាយភ្នែនសង្រួមភាវនាវេទមន្តជបបានឆ្មាញីមួយសម្បុរបី អំពីលោហិតរដូវដែលនាងផ្ចិតឲ្យទៅនោះ ។ រួចស្រេចហើយ ឥសីហៅនាងឧត្តរបុប្ផាមក ហើយលើកឆ្មាហុចមកឲ្យនាងប្រាប់នាងថា " នេះជាគ្នារបស់នាងហើយ សត្វនេះឈ្មោះថា ឆាម៉ា " ។ សត្វនោះចេះនិយាយគួរសមជាមួយនាង នាងក៏ទទួលយកមកថែរក្សាដោយសេចក្តីស្រឡាញ់ពេញចិត្ត ទុកដូចជាកូន ឬប្អូនឱបដល់ឱរាបីយកទៅក្នុងបន្ទប់ ទៅណាមកណា តែងយកទៅតាម និយាយគ្នាបីដូចមនុស្សដូច្នោះ ។ លុះដល់នាងអាយុបាន ១៧ ឆ្នាំ ទើបឥសីដាក់កំណត់ច្បាប់មាត្រា ឲ្យនាងកាន់កុំឲ្យភាន់ច្រឡំ សម្រាប់ជាច្បាប់តទៅកូនចៅស្រី ៗ ឯក្រោយទៀត គឺថាជាតិជាស្រីទាំងអម្បាលម៉ាន មិនត្រូវទាត់សត្វឆាម៉ានេះនឹងជើង ឬវាយនឹងអម្បោស ឬមួយនឹងត្របុតត្រីអាំង ។ កុំថាតែទាត់ធាក់ សូម្បីតែដើរកន្លងក៏មិនបានដែរ ត្បិតសត្វនេះកើតឡើងដោយ

លក្ខណ៍ស្រី ។ បើស្រីណាទាត់ធាក់ ឬដើរកន្លងសត្វនេះ ហៅថាស្រីហីនលក្ខណ៍ ហើយបើប្រព្រឹត្តិច្រើនដង ទៅ ហៅថាស្រីខាតលក្ខណ៍ ។ តមកប្រមាណ ១៤ ខែ សត្វឆាម៉ាក៏កើតបានកូនឈ្មោលមួយឡើងទៀត ។ គឺជាឆាម៉ាទាំងពីរនេះហើយ ជាកំណើតឆ្មាទាំងអស់ ។

និយាយពីស្តេចមួយអង្គនាមសោទត្ត ព្រះរាជបិតាលើករាជសម្បត្តិ ឲ្យកូននេះសោយរាជ្យសម្បត្តិឲ្យកូននេះសោយរាជ្យ ពីព្រះជន្មបាន ២១ ព្រះវស្សា នៅនគរឈ្មោះតក្កសីលា ។ ស្តេចថ្មីនោះសោយរាជ្យឡើងពុំមានមហេសីទេ ត្រអាលក្រសាលតែនឹងស្រីស្នំបរិពារ ។ លុះអង្វែងទៅ ស្តេចទ្រង់ផ្ទំវេលាយប់មួយ លោកនឹកភ្នកព្រះទ័យចង់ចេញទៅលេងព្រៃ ។ លុះភ្លឺស្វាងកាលណា ស្តេចក៏ចេញចុងព្រះរាជរោង ឲ្យនាម៉ឺនមុខមន្ត្រីគាល់ដូចសព្វដង ។ លុះជួបជុំមន្ត្រីអស់ហើយ ស្តេចក៏មានបន្ទូលប្រាប់ថា " យើងចង់ទៅលេងព្រៃនៅថ្ងៃខានស្អែក ចូររៀបចំពលថ្មើរជើងនិងសេះដំរី រៀបចំស្បៀងអាហារក្រយាស្ងោយគ្រាន់គ្រប់គ្នាកុំឲ្យខ្វះ" ។ នាម៉ឺនទទួលព្រះរាជឱង្ការកាលណា ក៏រៀបចំប្រដាប់ឥតមានខ្វះ ពលថ្មើរជើង ពលសេះដំរី រួចស្រេចហើយក៏ចូលក្រាបបង្គំទូលព្រះអង្គជ្រាប ។ លុះដល់កំណត់ថ្ងៃហើយ វេលាព្រឹកស្តេចក៏យាងចេញទៅ ដោយមាននាម៉ឺនសេនាទាហានហែតាម លុះបានបួនថ្ងៃក៏បានទៅដល់ ព្រៃហេមវន ស្តេចក៏មានព្រះឱង្ការឲ្យបោះ ព្រះពន្លាមួយនៅទីនោះ ។ អស់ទាំងសេនាទាហានក៏ធ្វើជំរំគ្រប់ ៗ តាមមុខរបស់ខ្លួនស្រេច ហើយស្តេចមានបន្ទូលបើកអំណាចឲ្យអស់សេនាលេងល្បែង-ភ្លេងច្រៀងរាំតាម ចិត្តឲ្យសប្បាយក្នុងព្រៃនោះ ។ នៅពេលយប់ស្តេចក៏ចូលផ្ទំ ក្នុងព្រះពន្លាជ័យ លុះអាធ្រាត្រស្ងាត់ឮសូរតែមាត់បក្សីគ្រប់ភាសាយំ មុខគួរឲ្យស្រងេះស្រងោច លន្លង់លន្លោចក្នុងព្រះទ័យមមៃនឹកគិតគ្រប់សព្វ លុះភ្លឺស្វាងព្រះសុរិយាកាលណា ស្តេចក៏មានព្រះរាជឱង្ការ បង្គាប់ទៅរាជអាមាត្យ ឲ្យរៀបទីន័ងអស្សតរថ្វាយ ព្រះអង្គនឹងត្រេចមើលព្រៃកម្សាន្តព្រះទ័យជាមួយនឹងអាមាត្យពីរនាក់ បីនឹងស្តេច ។ រួចហើយចេញទៅ ល្ងាចត្រឡប់មកព្រះពន្លាជ័យវិញ ។ គ្រប់បីថ្ងៃនៅវេលាព្រឹក ១ ស្តេចក៏បរទីន័ងទៅដល់ស្រះកំណើតនៃនាងឧត្តរបុប្ផា ទ្រង់ទតទៅឃើញ ទឹកក៏រងថ្លា ឃើញបុប្ផានិងមច្ឆាគ្រប់បែប ហែបហែលជ្រួល ច្រវាត់មុខគួរឲ្យទ្រង់សព្វព្រះទ័យនឹងចុះស្រង់ ។ ទើបស្តេចមានបន្ទូល ទៅរាជអាមាត្យទាំង ២ ថា យើងងូតទឹកស្រះនេះឲ្យត្រជាក់កាយសប្បាយចិត្តសឹមបន្តដំណើរទៅ ទើបឈប់លែងពាជីឲ្យស៊ីស្មៅ រួចផ្លាស់ព្រះពស្ត្រស្រង់ទៀត ព្រមទាំងរាជអាមាត្យ ទឹកក៏ត្រជាក់ធ្វើឲ្យមានកម្លាំងមែន ។ រួចហើយឡើងផ្លាស់ព្រះពស្ត្រស្រេច ស្តេចក៏យាងទតតាមឆ្នេរស្រះទៅ ឃើញមានផ្លូវទក់ ៗ ព្រះអង្គនឹកថា "យី ! ព្រៃនេះសមសាន្តឋានស្ងាត់ណាស់ ម្តេចឡើយក៏មានផ្លូវមនុស្សដើរដូច្នោះ" ។ រួចស្តេចក៏មានបន្ទូលទៅនឹងអាមាត្យថា នៅចាំយើងទីនេះចុះ យើងដើរទៅមើលត្រង់នោះបន្តិច ។ ស្តេចយាងតាមផ្លូវព្រះឥសីនោះទៅ ៗ បន្តិចបានក្រឡេកឃើញអាស្រម ស្តេចនឹកក្នុងព្រះទ័យថា រោងនេះជារោងអី ? ជាផ្ទះព្រានព្រៃទេ ឬអ្វី ? ព្រះអង្គចេះតែយាងចូលទៅ ឯព្រះឥសីកំពុងឆាន់ នាងឧត្តរបុប្ផាអង្គុយគាល់លោកតា ។ លុះស្តេចយាងដល់ទទួលនាងនោះក្រឡេកភ្នែកមកឃើញ នាងក៏ស្ទុះចូលទៅក្នុងបន្ទប់ ។ ព្រះឥសីសួរទៅនាងថា ម្តេចក៏ស្ទុះរត់ចូលក្នុង? នាងនិយាយតិច ៗ ទូលឥសីថា "មានមនុស្សពីណាដើរចូលមក"។ ព្រះឥសីក៏បែរព្រះភក្ត្រទតយល់ដូចនាងទូលមែន។ ឯព្រះរាជា លុះយល់ច្បាស់ដូច្នេះហើយ ក៏ចូលទៅថ្វាយបង្គំព្រះឥសី, ឥសីក៏ឈប់ឆាន់ សួរទៅស្តេចថា នែថៅមកពីណា បានជាចូលមកដល់ទីនេះ ?" ទើបស្តេចទូលឥសីថា " ខ្ញុំព្រះករុណាមកពីនគរតក្កសីលា " ឥសីឈ្វេងយល់មួយរំពេចថា នេះជាស្តេច ទើបព្រះអង្គសួរទៅទៀតថា " ស្តេចថៅមកទីនេះប្រាថ្នាអ្វី " ។ ព្រះបាទសោទត្ត ទូលឥសីតាមដំណើរ ឯឥសីឈ្វេងយល់

ថា ស្ដេចអង្គនេះត្រូវជាគូរនាងឧត្តរបុប្ផា លោកក៏ហៅចៅស្រីឲ្យចេញមកថ្វាយបង្គំព្រះរាជា ។ ហេតុតែនាងជាស្រីមានលក្ខណ៍ ក៏ចេញមកថ្វាយបង្គំព្រះរាជាតាមពុទ្ធដីកា ។ ព្រះអង្គក្រឡេកយល់នាង នាងក៏យល់ព្រះភក្ត្រព្រះអង្គច្បាស់ ហើយចាប់ចិត្តទៅវិញទៅមក ទើបព្រះឥសីមានពុទ្ធដីកាថា " ស្ដេចចៅនេះហើយដែលជាគូនឹងនាង តាំងតែអំពីអតីតជាតិមកម៉្លេះ " ។ គ្រានោះឥសីសួររកសេនារេហ៍ពល ព្រះបាទសោទត្ថក៏ទូលថា ព្រះអង្គយកតែអាមាត្យពីរនាក់មកតាមទេ ឥឡូវឲ្យឈប់ចាំនៅឯមាត់ស្រះខាងទិសឧត្តរឯណោះ ត្រង់ថាខ្ញុំករុណាត្រូវជាគូស្រករនឹងនាងនេះ ក៏ស្រេចតែលោកតា បើសព្វព្រះទ័យយ៉ាងណា ខ្ញុំព្រះករុណាទទួលធ្វើតាមទាំងអស់ ។ ឥសីបញ្ជាទៅវិញថា " បើដូច្នេះ សូមស្ដេចចៅថយ ទៅរៀបចំសង់រោងបីល្វែង ហើយរកផ្កាឲ្យបាន ៧ ពណ៌យកមកចងផ្ដុំជាបីបាច់ ទុកឲ្យតាទៅប្រសិទ្ធិពរជ័យឲ្យបានគ្នាជាប្ដីប្រពន្ធសុខសប្បាយតទៅ " ។

ស្ដេចស្ដាប់ព្រះពុទ្ធដីកាហើយ ក៏រួសរាន់ថ្វាយបង្គំលា យាងមកដល់ទីកន្លែងស្រះដែលឲ្យអាមាត្យចាំ ហើយបបួលអាមាត្យត្រឡប់ទៅកាន់ពន្លាជ័យវិញ ដល់ហើយបញ្ជានាម៉ឺនសេនាគ្រប់ក្រុម ឲ្យរៀបចំសង់រោងបីល្វែង តាមបង្គាប់ឥសី ។ បានរួចស្រេច ក៏ឲ្យក្បួនទ័ពព្រមទាំងភ្លេងដូរ្យតន្ត្រីពីរោះល្វឹងល្វើយ ទៅដង្ហែនាងឧត្តរបុប្ផាពីអាស្រមឥសី និមន្តទាំងព្រះឥសីឡើងគង់ព្រះវរសលៀងដង្ហែមកកាន់ព្រះពន្លា ។ ដល់ហើយព្រះតាបសតាំងសូត្រទិព្យមន្ត ព្រះឥសីក៏បាចផ្កាទាំង ៧ ពណ៌នោះថ្វាយពរជ័យដល់គូស្រករថ្មី ។ បីថ្ងៃតមកទើបព្រះអង្គនិងនាងជាយាថ្វាយបង្គំលាលោកតា នាងក៏ស្រក់ទឹកភ្នែកនឹកអាល័យលោកតា ព្រោះតាំងពីកើតមក ពុំដែលបែកទៅណាសោះ ឥឡូវមិនដឹងជាកាលណានឹងបានមកថ្វាយបង្គំវិញទេ ។

គ្រានោះ ឥសីបានផ្ដាំនាងថា៖ បើនាងទៅដល់ប្រាសាទហើយ មុននឹងឡើងទៅលើប្រាសាទ នាងត្រូវឱបសត្វឆាម៉ា ហើយដើរព័ទ្ធប្រទក្សិណប្រាសាទ ៣ ជុំ រួចសឹមឡើងទៅនៅក្នុងប្រាសាទនោះ ទើបនាងបានសុខមានសិរីសួស្ដី ។ នាងស្ដាប់សព្វគ្រប់ហើយ ក៏លាចេញទៅ លុះទៅដល់ព្រះរាជវាំងហើយ មុននឹងចូលក្នុងព្រះរាជដំណាក់ព្រះនាងបានធ្វើតាមបណ្ដាំឥសីឥតឲ្យឆ្គង ក៏បានប្រកបដោយសេចក្ដីសុខចម្រើនរហូតទៅ ។

ទំនងជាដោយសាររឿងនេះទេដឹង បានជាខ្មែរយើងមានទំនៀមមួយ ក្នុងពេលធ្វើពិធីឡើងផ្ទះថ្មី គឺគេនិយមឱបឆ្មាមួយ ហើយដើរប្រទក្សិណផ្ទះបីជុំ ហើយស្រេច ទើបគេឡើងនៅ ។